## រឿងទី៥៖ ប្រាសាទបាបិល

**ខគម្ពីរ៖ លោកុប្បត្តិ១១៖៩**

ហេតុនេះហើយបានជាគេដាក់ឈ្មោះក្រុងនោះថា "បាបិល" ដ្បិតនៅទីនោះហើយដែលព្រះអម្ចាស់បានបំបែកភាសារបស់មនុស្សលោកទាំងមូល ហើយព្រះអង្គធ្វើឲ្យមនុស្សបែកខ្ញែកគ្នាចេញពីទីនោះទៅពាសពេញលើផែនដីទាំងមូល។

ក្រោយទឹកជំនន់ធំនាន់ណូអេត្រូវបានបញ្ចប់ ពេលវេលាចេះតែកន្លងទៅ ថ្ងៃមួយក៏បានមកដល់។
កូនចៅរបស់ណូអេកាន់តែចម្រើនឡើងលើផែនដី ពួកគេរស់នៅជាមួយគ្នា និងនិយាយភាសាតែមួយដូចគ្នា។ ពួកគេទាំងនោះបានធ្វើដំណើរទៅទិសខាងកើត
ហើយបានមកជុំគ្នានៅវាលរាបមួយក្នុងស្រុកស៊ីណើរ តាំងទីលំនៅនៅទីនោះ។
មនុស្សជាច្រើនមករស់នៅជុំគ្នា ហើយចិត្តរបស់ពួកគេក៏កាន់តែធំឡើងៗ
មនុស្សកាន់តែមានប្រាជ្ញា ពួកគេកាន់តែមានចិត្តធំនៅចំពោះព្រះជាម្ចាស់។
ពួកគេគិតថា ពួកគេអាចខ្ពស់ខ្ពង់ដូចជាព្រះជាម្ចាស់បាន។
អស់មនុស្សដែលមានចិត្តលោភលន់កាន់តែខ្លាំងនោះ ពួកគេចាប់ផ្តើមសាងសង់ប្រាសាទដ៏សែនខ្ពស់។
ពួកគេបានចាប់ផ្តើមសាងសង់ប្រាសាទ ដែលខ្ពស់ដល់ផ្ទៃមេឃ។
មនុស្សម្នា សាងសង់ប្រាសាទដ៏ធំនិងខ្ពស់នេះ ដោយមិនទូលសួរព្រះជាម្ចាស់ថាទ្រង់សព្វព្រះទ័យឬអត់ឡើយ។
មនុស្សទាំងអស់ កាន់តែមានអំណួត ចិត្តកោតខ្លាចព្រះជាម្ចាស់ក៏កាន់តែបាត់អស់ទៅ។
ព្រះជាម្ចាស់បានទតឃើញមនុស្សទាំងអស់នោះកំពុងសាងសង់ប្រាសាទ។
ប៉ុន្តែ ក្នុងព្រះនេត្រទ្រង់ មិនឃើញថាវាជាកិច្ចការដ៏ល្អនោះទេ។
ដូច្នេះហើយ ព្រះជាម្ចាស់បានធ្វើឱ្យពួកគេនិយាយភាសាផ្សេងពីគ្នា។ ពេលនោះ មនុស្សទាំងអស់នោះ មិនយល់ពីភាសាដែលពួកគេនិយាយនោះទាល់តែសោះ។
ការយល់ច្រឡំកាន់តែខ្លាំងទៅៗ ក៏កើតមានជម្លោះ ធ្វើឱ្យពួកគេមិនអាចធ្វើការជាមួយគ្នាបានទៀត។
ហើយប្រាសាទដែលពួកគេចង់សាងសង់ឱ្យខ្ពស់រហូតដល់មេឃនោះក៏ត្រូវបានបញ្ឈប់ ម្នាក់ៗចាប់ផ្តើមបែកខ្ញែកគ្នារស់នៅរៀងៗខ្លួន។ ក្រោយមានការអស្ចារ្យនេះកើតឡើងរួចហើយ ទើបធ្វើឱ្យពួកគេដឹងថា ព្រះជាម្ចាស់ទ្រង់គឺខ្ពង់ខ្ពស់និងអស្ចារ្យជាងអ្វីទាំងអស់។ ហើយប្រាសាទដែលត្រូវបានសាងសង់ជាមួយគ្នានោះ ត្រូវបានគេហៅថា «ប្រាសាទបាបិល»។



**សកម្មភាពទី១** សូមឆ្លើយសំណួរខាងក្រោម។

a. តើប្រាសាទដ៏ខ្ពស់ដែលមនុស្សបានសាងសង់នោះ មានឈ្មោះអ្វី?

---------------------------------------------------------------

b. តើមនុស្សសាងសង់ប្រាសាទដ៏ខ្ពស់នោះ ដើម្បីអ្វី?

---------------------------------------------------------------

c. តើព្រះជាម្ចាស់បានបញ្ឈប់មនុស្សដែលសង់ប្រាសាទបាបិលដោយវិធីណា?

---------------------------------------------------------------

- សូមអានខគម្ពីរខាងក្រោម រួចទន្ទេញ។ (លោកុប្បត្តិ១១៖៩)

> ហេតុនេះហើយបានជាគេដាក់ឈ្មោះក្រុងនោះថា “បាបិល” ដ្បិតនៅទីនោះហើយដែលព្រះអម្ចាស់បានបំបែកភាសារបស់មនុស្សលោកទាំងមូល



**សកម្មភាពទី២** តើអ្នកនឹងប្រើឥដ្ឋអ្វីខ្លះដើម្បីសង់ប្រាសាទដ៏រឹងមាំសម្រាប់ព្រះរាជរបស់ព្រះជាម្ចាស់? សូមគូសសញ្ញា X លើឥដ្ឋដែលអ្នកនឹងប្រើប្រាស់។



## សកម្មភាពទី៣

សូមគិតពីខ្លឹមសារមេរៀនដែលបានរៀននៅថ្ងៃនេះ រួចផាត់ពណ៌រូបភាពខាងក្រោម។



